**Cambodian - Postpartum Hair Loss**

ជម្ងឺកើតមាននៅក្នុងចំណោមមនុស្សជំទង់



# ជម្ងឺជ្រុះសក់ក្រោយពីសំរាលកូន

## ចំណុចសំខាន់ៗ

- ជម្ងឺជ្រុះសក់ក្រោយពីសំរាលកូន មិនមែនជាការជ្រុះសក់ជាអចិន្ត្រៃយ៍នោះទេ
- តាមធម្មតាមានសក់ប្រហែលជា១០០,០០០សរសៃ ដុះនៅលើស្បែកលលាដ៏ក្បាល ហើយជាទូទៅមានសក់ប្រហែលជា៥០-២០០សរសៃ ជ្រុះរៀងរាល់ថ្ងៃ
- ការកើនកំរិតជាតិអ័រម៉ូន (hormone) នៅពេលមានផ្ទៃពោះ ធ្វើឲ្យសក់នៅស្បែកលលាដ៏ក្បាលដុះច្រើនជាងធម្មតា
- ក្រោយពីសំរាលកូនហើយ កំរិតជាតិអ័រម៉ូន ក៏ត្រឡប់ទៅភាពធម្មតាវិញ ហើយពីរ ទៅបីខែក្រោយមកក៏មានសក់ជ្រុះច្រើនឡើងកើតមាន អស់រយៈពេលពីរ ទៅបីខែ
- ការដុះសក់នឹងត្រឡប់មកធម្មតាវិញ ចាប់ពីបី ទៅប្រាំមួយខែបន្ទាប់ពីសក់ចាប់ផ្តើមជ្រុះ
- ជម្ងឺជ្រុះសក់ក្រោយពីសំរាលកូន អាចកើតមានរៀងរាល់ពេលមានផ្ទៃពោះ

## តើវាជាអ្វី?

ស្ត្រីជាច្រើននឹងកត់សំគាល់ឃើញមានការជ្រុះសក់បន្ទាប់ពីមានផ្ទៃពោះ។ ជាតិអ័រម៉ូនដែលកើនឡើងនៅពេលមានផ្ទៃពោះ នាំឲ្យមានការប្រែប្រួលនៅស្បែក និងផ្នែកឯទៀតជាច្រើននៃដងខ្លួន។ វាហាក់ដូចជាធ្វើឲ្យសក់ស្បែកលលាដ៏ក្បាលទាំងអស់ ចូលដល់ដំណាក់ការដុះសក់នៃសក់ដែលត្រូវដុះឡើងវិញនោះ។ ការនេះមានន័យថាស្ត្រីជាច្រើនសង្កេតឃើញសក់របស់ខ្លួន ហាក់បីដូចជាដុះក្រាស់នៅពេលមានផ្ទៃពោះ។

ក្រោយពីទារកបានកើតមក សក់ជាច្រើនក៏ឈប់ដុះ ហើយក៏ចូលដល់ដំណាក់ការសំរាក ដែលវាស្ថិតនៅដដែលអស់រយៈពេលពីរ ទៅបីខែ។ កាលណាការដុះសក់ឡើងវិញចាប់ផ្តើមជាថ្មី នោះសក់ក៏វិលត្រឡប់ចូលក្នុងដំណាក់ការដុះ ហើយសក់ចាស់ក៏ចាប់ផ្តើមជ្រុះក្នុងពេលជាមួយគ្នាភ្លាម។ ចំនួននៃការជ្រុះសក់នឹងប្រែប្រួលស្របទៅតាមបុគ្គលម្នាក់ៗ ដែលមានស្ត្រីខ្លះសង្កេតឃើញសក់របស់ខ្លួន ជ្រុះច្រើនជាងសក់ស្ត្រីឯទៀត។ ប្រសិនបើមានទំនោរទៅរកសក់ស្តើងកើតមាននៅក្នុងគ្រួសារ ការជ្រុះសក់ក៏អាចឃើញកាន់តែច្បាស់បន្ទាប់ពីទារកបានកើតមក។

ជម្ងឺជ្រុះសក់ក្រោយពីសំរាលកូន ជាទូទៅកើតមានអស់រយៈពេលពីរ ទៅបីខែ បន្ទាប់មកសក់ក៏ចាប់ផ្តើមដុះសារជាថ្មីឡើងវិញ។ នៅក្នុងចំណោមស្ត្រីភាគច្រើន សក់វិលត្រឡប់មករកភាពដូចមុនពេលមានផ្ទៃពោះ។

## វាគេព្យាបាលវាដោយរបៀបណា?

ពុំចាំបាច់ត្រូវការព្យាបាលជម្ងឺជ្រុះសក់ក្រោយពីសំរាលកូនឡើយ។ វាគ្រាន់តែជាការផ្លាស់ប្តូរបណ្តោះអាសន្ន នៅក្នុងដំណើរសក់ជ្រុះដែលត្រូវដុះឡើងវិញប៉ុណ្ណោះ ដែលបណ្តាលមកពីការប្រែប្រួលជាតិអ័រម៉ូននៅពេលមានផ្ទៃពោះ។

ការត្រដុះសក់ និងសិតសក់ច្រើនហួសហេតុ នឹងរំលើងសក់ចេញយ៉ាងងាយ ព្រមទាំងបង្កើនល្បឿនជ្រុះសក់ចេញពីក្បាលផង ដែលតាមធម្មតាវាត្រូវប្រើពេលពីរ ទៅបីខែ។ ទោះបីជាយ៉ាងណាក្តី ប្រសិនបើការនេះកើតឡើង នោះវានឹងមិនធ្វើឲ្យខូចសក់ក្នុងបែបណាមួយឡើយ។ ការប្រើថ្នាំវីតាមីន ឬថ្នាំលាបនៅស្បែកលលាដ៏ក្បាល នឹងមិនធ្វើឲ្យខុសប្លែកអ្វីទេ។ ស្ត្រីខ្លះកត់សំគាល់ឃើញថាជម្ងឺជ្រុះសក់ក្រោយពីសំរាលកូន កើតមានរៀងរាល់ក្រោយពេលមានផ្ទៃពោះ។

## ពត៌មានបន្ថែមទៀត

- គិលានុបដ្ឋាយិកាមើលថែទាំសុខភាពមាតា និងកុមារ
- វេជ្ជបណ្ឌិតប្រចាំគ្រួសាររបស់លោកអ្នក
- អ្នកឯកទេសខាងសំរាលកូន

© 2002, Department of Dermatology, St. Vincent's Hospital Melbourne, Victoria Parade, Fitzroy, Victoria 3065 Australia.